# ការពណ៌នាអំពីមង្គល

## (បិដក ៤១ ទំព័រ ៤៧៥ និង អដ្ឋកថា)



ការផ្សាយចេញពីវត្តស្រះមុច្ចលិន្ទ ហៅកោះត្រើង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល

រៀបរៀងដោយភិក្ខុ សារត្ថធម្មោ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២២

# មាតិកាធម៌ក្នុងសៀវភៅនេះ


| ល.រ | ឈ្មោះធម៌ | ទំព័រ |
|---|---|---|
| ១ | ធម៌នាំឲ្យកើតក្នុងនរក ៣ យ៉ាង | ៤ |
| ២ | ធម៌នាំឲ្យកើតក្នុងស្ថានសួគ៌ ៣ យ៉ាង | ៤ |
| ៣ | ធម៌មិនមានទោស ៣ យ៉ាង | ៤ |
| ៤ | ធម៌មានទោស ៣ យ៉ាង | ៥ |
| ៥ | ធម៌មិនរាបសា ៣ យ៉ាង | ៦ |
| ៦ | ធម៌ស្អាត ៣ យ៉ាង | ៦ |
| ៧ | ធម៌របស់អសប្បុរស ៣ យ៉ាង | ៦ |
| ៨ | ធម៌របស់សប្បុរស ៣ យ៉ាង | ៨ |
| ៩ | ធម៌របស់បុគ្គលពាល ៣ យ៉ាង | ៨ |
| ១០ | ធម៌របស់បុគ្គលជាបណ្ឌិត ៣ យ៉ាង | ៨ |
| ១១ | ការថ្វាយបង្គំ ៣ យ៉ាង | ១០ |
| ១២ | ការពោលអំពីនក្ខត្តឫក្សល្អជាដើម | ១២ |
| ១៣ | អដ្ឋកថាពោលអំពីនក្ខត្តឫក្សល្អជាដើម | ១៤ |
| | | |

# មង្គលវគ្គោ

[១៤៨] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ តីហិ ។ អកុសលេន កាយកម្មេន អកុសលេន វចីកម្មេន អកុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ តីហិ ។ កុសលេន កាយកម្មេន កុសលេន វចីកម្មេន កុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[១៤៩] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ សាវជ្ជេន កាយកម្មេន សាវជ្ជេន វចីកម្មេន សាវជ្ជេន មនោកម្មេន ។ បេ ។ អនវជ្ជេន កាយកម្មេន អនវជ្ជេន វចីកម្មេន អនវជ្ជេន មនោកម្មេន ។ បេ ។

# មង្គលវគ្គ

[១៤៨] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាអកុសល ១ វចីកម្ម ជាអកុសល ១ មនោកម្ម ជាអកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាកុសល ១ វចីកម្ម ជាកុសល ១ មនោកម្ម ជាកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ។ បេ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមាន ទោស ១ មនោកម្មមិនមានទោស ១ ។ បេ ។

[១៨០] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ វិសមេន កាយកម្មេន វិសមេន វចីកម្មេន វិសមេន មនោកម្មេន ។ បេ ។ សមេន កាយកម្មេន សមេន វចីកម្មេន សមេន មនោកម្មេន ។ បេ ។

[១៨១] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ អសុចិនា កាយកម្មេន អសុចិនា វចី-កម្មេន អសុចិនា មនោកម្មេន ។ បេ ។ សុចិនា កាយកម្មេន សុចិនា វចីកម្មេន សុចិនា មនោ-កម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។

[១៨២] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ តីហិ ។ អកុសលេន កាយកម្មេន អកុសលេន វចីកម្មេន អកុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ

[១៥០] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនរាបសា ១ វចីកម្មមិនរាបសា ១ មនោកម្មមិនរាបសា ១ ។ បេ ។ កាយកម្មរាបសា ១ វចីកម្មរាបសា ១ មនោកម្មរាបសា ១ ។ បេ ។

[១៥១] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនស្អាត ១ វចីកម្មមិនស្អាត ១ មនោកម្មមិនស្អាត ១ ។ បេ ។ គឺកាយកម្មស្អាត ១ វចីកម្មស្អាត ១ មនោកម្មស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ដូចជាគេនាំយកទៅតម្កល់ទុក ។

[១៥២] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឆ្លៀវឆ្លាស ជាអសប្បុរសប្រកបដោយធម៌ ៣ យ៉ាង រមែងរក្សាខ្លួនដែលខ្លួនគាស់រំលើងផ្តាច់ផ្តិល (នូវគុណ) ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបាបជាច្រើនផង ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាអកុសល ១ វចីកម្ម ជាអកុសល ១ មនោកម្ម ជាអកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឆ្លៀវឆ្លាស ជាអសប្បុរស ប្រកបដោយធម៌ ៣ យ៉ាងនេះឯង

ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេហិ តីហិ ។ កុសលេន កាយកម្មេន កុសលេន វចីកម្មេន កុសលេន មនោកម្មេន ។ បេ ។

[១៨៣] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ សាវជ្ជេន កាយកម្មេន សាវជ្ជេន វចី-កម្មេន សាវជ្ជេន មនោកម្មេន ។ បេ ។ អនវជ្ជេន កាយកម្មេន អនវជ្ជេន វចីកម្មេន អនវជ្ជេន មនោកម្មេន ។ បេ ។

[១៨៤] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ វិសមេន កាយកម្មេន វិសមេន វចី-កម្មេន វិសមេន មនោកម្មេន ។ បេ ។ សមេន កាយកម្មេន សមេន វចីកម្មេន សមេន មនោកម្មេន ។ បេ ។

រមែងរក្សាខ្លួន ដែលខ្លួនគាស់រំលើងផ្តាច់ផ្តិល (នូវគុណ) ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបាបជាច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឆ្លៀវឆ្លាសជាសប្បុរស ប្រកបដោយធម៌ ៣ យ៉ាង រមែងរក្សាខ្លួនដែលមិនគាស់រំលើងមិនផ្តាច់ផ្តិល (នូវគុណ) ជាអ្នកមិនមានទោសផង មិនមានដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបុណ្យជាច្រើនផង ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាកុសល ១ វចីកម្ម ជាកុសល ១ មនោកម្ម ជាកុសល ១ ។ បេ ។

[១៥៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ។ បេ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ។ បេ ។

[១៥៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនរាបសា ១ វចីកម្មមិនរាបសា ១ មនោកម្មមិនរាបសា ១ ។ បេ ។ គឺកាយកម្មរាបសា ១ វចីកម្មរាបសា ១ មនោកម្មរាបសា ១ ។ បេ ។

[១៨៥] តីហិ ភិក្ខវេ ។ បេ ។ អសុចិនា កាយ-កម្មេន អសុចិនា វចីកម្មេន អសុចិនា មនោ-កម្មេន ។ បេ ។ សុចិនា កាយកម្មេន សុចិនា វចីកម្មេន សុចិនា មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

[១៨៦] តិស្សោ ឥមា ភិក្ខវេ វន្ទនា ។ កតមា តិស្សោ ។ កាយេន វាចាយ មនសា ។ ឥមា ខោ ភិក្ខវេ តិស្សោ វន្ទនាតិ ។

[១៨៧] យេ ភិក្ខវេ សត្តា បុព្វណ្ហសមយំ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុបុព្វណ្ហោ ភិក្ខវេ តេសំ សត្តានំ

[១៥៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនស្អាត ១ វចីកម្មមិនស្អាត ១ មនោកម្មមិនស្អាត ១ ។ បេ ។ គឺកាយកម្មស្អាត ១ វចីកម្មស្អាត ១ មនោកម្មស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឆ្លៀវឆ្លាស ជាសប្បុរស ប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលមិនបានគាស់រំលើង មិនផ្តាច់ផ្តិល (នូវគុណ) ជាអ្នកមិនមានទោសផង មិនមានដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបុណ្យជាច្រើនផង ។

[១៥៦] ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំនេះ មាន ៣ យ៉ាង ។ ការថ្វាយបង្គំ ៣ យ៉ាងដូចម្តេចខ្លះ ។ គឺថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំមាន ៣ យ៉ាងនេះឯង ។

[១៥៧] ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងបុព្វណ្ហ-សម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានបុព្វណ្ហសម័យដ៏ល្អ

យេ ភិក្ខវេ សត្តា មជ្ឈន្តិកសមយំ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុមជ្ឈន្តិកោ ភិក្ខវេ តេសំ សត្តានំ យេ ភិក្ខវេ សត្តា សាយណ្ហសមយំ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុសាយណ្ហោ ភិក្ខវេ តេសំ សត្តានន្តិ ។

សុនក្ខត្តំ សុមង្គលំ
សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច
សុយិដ្ឋំ ព្រហ្មចារិសុ
បនក្ខិណំ កាយកម្មំ
វាចាកម្មំ បនក្ខិណំ
បនក្ខិណំ មនោកម្មំ
បណិធី តេ បនក្ខិណា
បនក្ខិណានិ កត្វាន
លភន្តត្ថេ បនក្ខិណេ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងមជ្ឈន្តិកសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានមជ្ឈន្តិកសម័យដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងសាយណ្ហសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានសាយណ្ហសម័យដ៏ល្អ ។

ពេលណា ដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចាចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ (ក្នុងថ្ងៃនោះ) កាយកម្មឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន វចីកម្ម ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន មនោកម្ម ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយ របស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន បុគ្គលដែលបានធ្វើ នូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ ដ៏ចម្រើនទាំងឡាយ ។

តេ អត្ថលទ្ធា សុខិតា

វិរូឡ្ហា ពុទ្ធសាសនេ

អរោគា សុខិតា ហោថ

សហ សព្វេហិ ញាតិភីតិ ។

មង្គលវគ្គោ បញ្ចមោ ។

*អ្នកទាំងឡាយនោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្ដីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឲ្យមានរោគ ឲ្យបាននូវសេចក្ដីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា ។*

ចប់ មង្គលវគ្គ ទី ៥ ។

# អដ្ឋកថា សុបុព្វណ្ហសូត្រទី ១០

## *“វេលាដែលជាឫក្សល្អ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុបុព្វណ្ហសូត្រទី ១០ ដូចតទៅនេះ ៖*

**[១៤៧]** *ក្នុងបទជាដើមថា* ***សុនក្ខត្តំ*** *(ឫក្សល្អ) មានអធិប្បាយថា ថ្ងៃដែលមនុស្សទាំងឡាយបំពេញសុចរិតធម៌ ៣ ឲ្យបរិបូរណ៍ ឈ្មោះថា ជាថ្ងៃដែលបានការប្រកបឫក្ស ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ថ្ងៃនោះជាឫក្សល្អគ្រប់កាល ។ ថ្ងៃនោះឯង ឈ្មោះថា ជាថ្ងៃធ្វើមង្គលហើយ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ថ្ងៃនោះជាមង្គលល្អគ្រប់កាល ។ សូម្បីថ្ងៃដែលមានសេចក្ដីភ្លឺស្វាងនោះ ក៏ឈ្មោះថា មានសេចក្ដីភ្លឺស្វាងល្អជាប្រចាំនោះឯង ។ សូម្បីការក្រោកឡើងពីដំណេក ក៏ឈ្មោះថា ក្រោកឡើងដោយល្អ ។ សូម្បីខណៈ ក៏ឈ្មោះថា ជាខណៈល្អ ។ សូម្បីយាម ក៏ឈ្មោះថា ជាយាមល្អ ។*

*ក៏ក្នុងបទថា* ***សុមុហុត្តោ*** *(យាមល្អ) នេះ គប្បីជ្រាបការបែងចែកវេលាដូច្នេះ វេលាប្រមាណ ១០ ផ្ទាប់ ឈ្មោះ ខណៈ ។ វេលា ១០ ខណៈ ដោយខណៈនោះ ឈ្មោះថា លយៈ ។ វេលា ១០ លយៈ ដោយលយៈនោះ ឈ្មោះថា ខណលយៈ ។ វេលា ១០ នោះ ដោយខណលយៈនោះ ឈ្មោះថា មុហុត្តៈ ។ វេលា ១០ នោះ ដោយមុហុត្តៈនោះ ឈ្មោះថា ខណមុហុត្តៈ ។*

បទថា **សុយិដ្ឋំ ព្រហ្មចារិសុ** (ឈ្មោះថាបូជាល្អក្នុងព្រហ្មចារីបុគ្គលទាំងឡាយ) សេចក្តីថា ទានដែលគេឲ្យក្នុងអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ក្នុងថ្ងៃដែលបំពេញសុចរិត ៣ ឲ្យបរិបូរណ៍ហើយ ឈ្មោះថា បូជាល្អហើយ ។ បទថា **បទក្ខិណំ កាយកម្មំ** (កាយកម្មជាជោគល្អ) សេចក្តីថា កាយកម្មដែលគេធ្វើហើយក្នុងថ្ងៃនោះ ឈ្មោះថា ជាកាយកម្មប្រកបដោយសេចក្តីចម្រើន ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **បទក្ខិណានិ កត្វាន** (ធ្វើកម្មទាំងឡាយដែលជាកម្មល្អ) សេចក្តីថា លុះធ្វើកាយកម្មជាដើម ដែលប្រកបដោយសេចក្តីចម្រើនហើយ ។ បទថា **លភន្តត្ថេ បទក្ខិណេ** (រមែងបានទទួលវត្ថុទាំងឡាយដែលល្អមានប្រយោជន៍) សេចក្តីថា រមែងបានវត្ថុដែលល្អ គឺ ប្រយោជន៍ដែលប្រកបដោយសេចក្តីចម្រើននុ៎ះឯង ។ អត្ថដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងអស់នោះឯង ។

**ចប់អដ្ឋកថា សុបុព្វណ្ហសូត្រទី ១០**

**ចប់មង្គលវគ្គទី ៩**